ក្រសួងការពារជាតិ
MINISTRY OF NATIONAL DEFENSE

រាជធានីភ្នំពេញថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**សូមផ្ញើជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ង៉ូ ស៊ុនលិច្យ** (Ngo Xuan Lich)

**រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងនាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល និងក្នុងនាមខ្ញុំផ្ទាល់ខ្ញុំពិតជាសោកសៅយ៉ាងក្រៃលែង ដោយទទួលដំណឹងថា កម្មាភិបាលជាន់ខ្ពស់ និងយុទ្ធជនមួយចំនួននៃកងទ័ពប្រជាជនវៀតណាម បានពលីជីវិតក្នុងបេសកកម្មចុះជួយសង្គ្រោះប្រជាជនពីគ្រោះមហន្តរាយធម្មជាតិដោយព្យុះ និងជំនន់ទឹកភ្លៀង នៅតំបន់ភូមិភាគកណ្តាល កាលពីប៉ុន្មានថ្ងៃកន្លងមកថ្មីៗនេះ។

ពលីកម្មដ៏ខ្ពង់ខ្ពស់របស់កម្មាភិបាលជាន់ខ្ពស់ និងយុទ្ធជននៃកងទ័ពប្រជាជនវៀតណាម គឺជាការបាត់បង់ដ៏ធំធេង និងគួរឱ្យគោរពកោតសរសើររបស់រដ្ឋាភិបាល និងប្រជាជនវៀតណាម ហើយក៏ជាការបាត់បង់មិត្តដ៏ល្អរបស់រាជរដ្ឋាភិបាល ប្រជាជន និងកងយោធពលខេមរភូមិន្ទផងដែរ។

យើងខ្ញុំចងចាំនូវវីរភាពដ៏អង់អាចក្លាហាន និងសូមឧទ្ទិសបួងសួងជូនដល់វិញ្ញាណក្ខន្ធកម្មាភិបាលជាន់ ខ្ពស់និងយុទ្ធជននៃកងទ័ពប្រជាជនវៀតណាម ដែលលះបង់ខ្ពស់ក្នុងបុព្វហេតុសង្គ្រោះមនុស្សជាតិ សូមឱ្យស្ថិតក្នុងសុគតិភពកុំបីឃ្លៀងឃ្លាត។

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងនាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល និងខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវសមានចិត្តចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុតជូនចំពោះបក្ស ប្រជាជន រដ្ឋ និងកងទ័ពប្រជាជនវៀតណាម ក៏ដូចជាជូនចំពោះក្រុមគ្រួសារនៃសពនូវការបាត់បង់កម្មាភិបាលជាន់ខ្ពស់ និងយុទ្ធជនមួយចំនួនជាទីគោរពស្រលាញ់នេះ ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចពិជ័យសេនា ទៀ បាញ់**